**គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការ_សមាគមការពារសិទ្ធិមនុស្សកម្ពុជា**

**CAMBODIAN HUMAN RIGHTS ACTION COMMITTEE**

ADHOC - CARAM Cambodia - CCPCR - CDP - CHHRA - CKIMHRDA - CSD - CWCC - GENEROUS - HROTP- IDA
KID - KIND - KKKHRA - KKKHRDA - KSA - KYA - LAC - OUTREACH – PDP - PJJ - TASK FORCE - VIGILANCE

#09, St 330, Sangkat Boeung Keng Kang3, Khan Chamcar Mon, Phnom Penh, Cambodia, Tel/Fax: 023 301 415 E-mail: chrac@forum.org.kh


# សេចក្តីថ្លែងការណ៍ ស្តីពី

## *គណៈកម្មាធិការប្រព្រឹត្តិកម្មអំពាវនាវឱ្យមានដំណោះស្រាយនយោបាយទៅលើករណីលោក សម រង្ស៊ី*

*ភ្នំពេញ ថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០*

គណៈកម្មាធិការប្រព្រឹត្តិកម្ម នៃ អង្គការសមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ដែលជាសម្ព័ន្ធនៃអង្គការ-សមាគមមិនមែនរដ្ឋាភិបាល ដែលមានសមាជិកចំនួន២៣ សូមសំដែងនូវការព្រួយបារម្ភជាខ្លាំងចំពោះការលេចចេញនូវការប្តឹងផ្តល់ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ជាថ្មីទៀត ទៅលើប្រធានគណបក្សជំទាស់ លោក **សម រង្ស៊ី** បន្ថែមលើបទចោទប្រកាន់ដែលទើបតែត្រូវបានកាត់សេចក្តីដោយតុលាការខេត្តស្វាយរៀង នាពេលកន្លងមកនេះ។

យោងទៅតាមការប្រកាសរបស់មេធាវីតំណាងរាជរដ្ឋាភិបាលកម្ពុជា ត្រូវបានគេជឿថា ពាក្យបណ្តឹងប្តឹងទៅលើអ្នកដឹកនាំគណបក្សជំទាស់លោក សម រង្ស៊ី ត្រូវបានដាក់ទៅអយ្យការនៃតុលាការ រាជធានីភ្នំពេញនាពេលថ្មីៗនេះទាក់ទិននឹងបទល្មើសថ្មីមួយចំនួនទៀត។ ការលេចលឺអំពីការប្តឹងផ្តល់ថ្មីនេះ កាន់តែធ្វើឱ្យសាធារណៈមតិជាតិ និង អន្តរជាតិ មានការព្រួយបារម្ភអំពីបញ្ហានយោបាយថ្មីៗនៅក្នុងប្រទេសកម្ពុជា ជាពិសេស ទាក់ទិននឹងលំហប្រជាធិបតេយ្យ និង តួនាទីរបស់អ្នកតំណាងរាស្ត្រ ជាពិសេស អ្នកតំណាងរាស្ត្រ នៃគណបក្សជំទាស់ដែលត្រូវរងនូវការប្តឹងផ្តល់តាមរយៈផ្លូវតុលាការជាហូរហែរ ខណៈពេលដែលបញ្ហាជាតិជាច្រើន កំពុងតែត្រូវការឱ្យមានការចូលរួមចំណែកដោះស្រាយពីអ្នកនយោបាយមកពីគ្រប់និន្នាការនយោបាយទាំងអស់។

ជុំវិញបញ្ហាទាំងនេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម យល់ឃើញថា អ្នកដឹកនាំនយោបាយខ្មែរមកពីគ្រប់និន្នាការនយោបាយ ឬ គណបក្សនយោបាយ គួរតែគិតគូរយកចិត្តទុកដាក់ទៅលើផលប្រយោជន៍របស់ប្រទេសជាតិជាធំ និងរួបរួមកំលាំងគ្នា តាមរយៈការផ្សះផ្សារជាតិមួយដ៏សំខាន់ ដើម្បីឈានទៅរកការដោះស្រាយបញ្ហាទាំងនេះដោយសន្តិវិធី។ ដូចនេះ ជុំវិញបញ្ហាដែលចេះតែកើតមានជាបន្តបន្ទាប់ក្នុងរយៈពេលនេះ គណៈកម្មាធិការប្រព្រឹត្តិកម្ម ក៏សូមធ្វើការអំពាវនាវស្នើសុំដល់អ្នកនយោបាយរបស់យើងឱ្យចេះយោគយល់គ្នាទៅវិញទៅមក និង ចេះចរចាគ្នាក្នុងភាពចាស់ទុំខាងនយោបាយ ដើម្បីដោះស្រាយបញ្ហាជាតិជារួមជាធំ ក៏ដូចជាដើម្បីឱ្យប្រជាពលរដ្ឋកម្ពុជាយើងរស់នៅក្នុងសន្តិភាព និងបរិយាកាសសង្គមប្រជាធិបតេយ្យមួយ ដែលរាជរដ្ឋាភិបាលកំពុងតែអះអាងប្រកាន់យក។


***សំរាប់ព័ត៌មានបន្ថែម សូមទាក់ទង:***

| | | |
|---|---|---|
| លោក **ហង្ស ឆាយា** | ប្រធានសំរបសំរួល CHRAC និង នាយកប្រតិបត្តិ KID | ទូរស័ព្ទលេខ: ០១២ ៨៦៥ ៩១០ |
| លោក **សុក សំអឿន** | នាយកប្រតិបត្តិអង្គការ CDP | ទូរស័ព្ទលេខ: ០១២ ៩០១ ១៩៩ |
| លោកស្រី **ស៊ុន ចាន់សែន** | ប្រធានសមាគម KYA | ទូរស័ព្ទលេខ: ០១៧ ៧៨៨ ៩៥៥ |
| លោកស្រី **សយ សារាវឌ្ឍនី** | នាយិកាប្រតិបត្តិអង្គការ CWCC | ទូរស័ព្ទលេខ: ០៩២ ៩៩៣ ៣៥៨ |
| លោក **នី ចរិយា** | អ្នកសំរបសំរួលកម្មវិធី នៃសមាគមអាដហុក | ទូរស័ព្ទលេខ: ០១១ ២៧៤ ៩៥៩ |